# ឈរលើស្មារតីសាមគ្គីភាព៖ ការជួយគាំទ្រដល់សហគមន៍ដ៏ចម្រុះរបស់មន្ទីរអប់រំឡុងប៊ីចយើង

ថ្ងៃទី18 ខែកុម្ភៈ ឆ្នាំ2025

ជូនចំពោះសិស្សានុសិស្ស មាតាបិតា អ្នកមើលថែ និងសហគមន៍ ជាទីរាប់អាន៖

មន្ទីរអប់រំឡុងប៊ីចប្រកាន់ជំហ៊រយ៉ាងមុតមាំ ក្នុងការគាំទ្រសិស្សដែលមានភេទខ្ទើយផ្សេងៗ បុគ្គលិក និងក្រុមគ្រួសារ - រួមជាមួយ សិស្សានុសិស្សគ្រប់រូប គ្រប់ក្រុមគ្រួសារទាំងអស់ និងសមាជិកបុគ្គលិកគ្រប់គ្នា-- ថ្ងៃនេះ និងជានិច្ចជាកាល ព្រមទាំង ការប្តេជ្ញាចិត្តចំពោះ ឧត្តមភាព និងសមធម៌ ដែលបំផុសគំនិត អ្វីៗគ្រប់យ៉ាងដែលយើងខ្ញុំធ្វើ។

ស្ថិតនៅចំពោះមុខបញ្ហាប្រឈមក្នុងសង្គម និងនយោបាយ ដែលប៉ុនប៉ងបំបែកបំបាក់ ជាជាងការបង្រួបបង្រួម យើងខ្ញុំសូមបញ្ជាក់ឡើងវិញ នូវជំហ៊រមិនងាករេរបស់យើងខ្ញុំ៖

- សិស្សគ្រប់រូម - ដោយមិនគិតអំពី និន្នាការភេទ ប្រវត្តិសាវតា ពិការភាព ស្ថានភាពអន្តោប្រវេសន៍ ពូជសាសន៍ ជំនឿ វប្បធម៌ ឬ ស្ថានភាពទីលំនៅឡើយ - គឺសក្តិសមនឹងទទួលបានការយោគយល់ មានអារម្មណ៍សុវត្ថិភាព និង ជួយគាំទ្រ ខណៈពេល ដែលស្ថិតនៅក្រោមការថែរក្សារបស់យើងខ្ញុំ។
- យើងខ្ញុំទាត់ចោល រាល់ការប៉ុនប៉ងធ្វើអោយខូចសេចក្តីថ្លៃថ្នូរ បង្កើតការបំបែកបំបាក់ ឬ បដិសេធសិទ្ធិដែលទទួលបានការអប់រំ ដែលមានលក្ខណៈរួមបញ្ចូលទាំងអស់គ្នា។

មន្ទីរអប់រំឡុងប៊ិច ប្តេជ្ញាចិត្តដើម្បីលើកកម្ពស់ការរួមបញ្ចូល សមធម៌ និង បរិយាកាសស្វាគមន៍ សម្រាប់ទាំងអស់គ្នា។
នេះមានន័យថា គឺធានាដល់សិស្សគ្រប់រូប គ្រប់គ្រួសារទាំងអស់ និង សមាជិកបុគ្គលិកគ្រប់គ្នា៖ ទូទាំងអត្តសញ្ញាណទាំងអស់ ប្រវត្តិសាវតា និងបទពិសោធន៍ជីវិតរស់នៅជាក់ស្តែង៖ មានសិទ្ធិទទួលបានព័ត៌មាន ឱកាស និង ការជួយគាំទ្រដែលពួកគេត្រូវការ ដើម្បីរីកចម្រើនបាន។

- នេះមានន័យថា ការលើកកំពស់សុវត្ថិភាព និងការបញ្ជាក់អំពីតម្លៃមនុស្សរបស់ សិស្សានុសិស្សភេទខ្ទើយផ្សេងៗ
- ក្រុមគ្រួសារ និងបុគ្គលិក។
- នេះមានន័យថា ការពង្រីក ការជួយគាំទ្រផ្លូវចិត្ត សំរាប់អ្នកទាំងឡាយណាដែលរងប៉ះទង្គិចផ្លូវចិត្ត ឬ មានទុក្ខលំបាក។
- នេះមានន័យថា ការដោះស្រាយវិសមភាពក្នុងការអប់រំពិសេស សមធម៌ពូជសាសន៍ និង ឱកាសសេដ្ឋកិច្ច ដើម្បី បិទកម្លាតសមិទ្ធិផលផ្សេងៗ។
- នេះមានន័យថា ការចូលរួមអបអរ និង គោរពដល់ការរួមចំណែកតែមួយគត់ របស់រាល់គ្រប់អត្តសញ្ញាណ ជាតិសាសន៍ វប្បធម៌ និង ប្រវត្តិសាវតា ដែលតំណាងនៅក្នុងសហគមន៍សាលារៀនរបស់យើង។

រួមគ្នាជាសហគមន៍តែមួយ យើងខ្ញុំបដិសេធចំពោះការស្អប់ខ្ពើម បំបែករនាំងឧបសគ្គ និងធ្វើការបង្កើតនូវការចិញ្ចឹមបីបាច់ និង ការទទួលយកនូវបរិយាកាសមួយ ដែលសិស្សគ្រប់រូប - ដោយគ្មានការលើកលែង - គឺអាចល្អឥតខ្ចោះ។ ទាំងនេះមិនមែនគ្រាន់តែជាទំនួលខុសត្រូវរប់យើងខ្ញុំប៉ុណ្ណោះទេ៖ គឺវាជាកាតព្វកិច្ចសិលធម៌របស់យើងទាំងអស់គ្នា។
សូមថ្លែងអំណរគុណចំពោះជំហរគាំទ្រ ជាមួយនឹងយើងខ្ញុំក្នុងសាមគ្គីភាព ក្តីស្រឡាញ់ និង ការជួយគាំទ្រដែលមិនងាករេ សំរាប់សមាជិកគ្រប់រូបរបស់សគមន៍មន្ទីរអប់រំឡុងប៊ីចទាំងមូល។

**~មន្ទីរអប់រំឡុងប៊ិច**